# អ្នកនាំសារ
THE MESSENGER

ពតិមានពីព្រះសហគមន៍កាតូលិក | Internal Use | ឆ្នាំទី ០២ លេខ ០៩ ខែ មករា ឆ្នាំ ២០០៤


# យើងត្រូវទឹកដល់គោលដៅជានិច្ច

មនុស្សយើងម្នាក់ៗ ដែលរស់រានមានជីវិតនៅលើលោកនេះ តែងតែមានគោលបំណងយ៉ាងតិចបំផុតមួយ ឬ ជូនកាលច្រើនទៀតផង។ ប៉ុន្តែក្នុងការរស់នៅ និងក្នុងសកម្មភាពប្រព្រឹត្តផ្សេងៗរបស់យើងរៀងរាល់ថ្ងៃជួនកាលនាំមកនូវអំណរសប្បាយ ជួនកាលនាំមកនូវការព្រួយបារម្ភ ទុក្ខកង្វល់ ឬជួនកាលត្រូវគេចាប់កំហុស ។ល។ សេចក្តីទាំងនេះតែងកើតឡើងក្នុងជីវិតរបស់មនុស្សម្នាក់ៗជៀសពុំរួចឡើយ ហើយវាក៏ជារឿងធម្មតាដែរព្រោះជីវិតមានការវិវត្តន៍រីកចំរើនជារៀងរាល់ថ្ងៃមិននៅនឹងថ្កល់នោះទេ។ ប៉ុន្តែអ្វីដែលសំខាន់ គឺយើងគួរចេះមើល និងចេះពិចារណានូវគោលបំណងរបស់យើងតើត្រឹមត្រូវ ឬ មិនត្រឹមត្រូវ? ហើយអ្វីដែលល្អ



ហោរាចារ្យទាំងបីទៅថ្វាយបង្គំព្រះកុមារយេស៊ូ "សំដែងដោយយុវជនកំពង់ចាម"

ប្រសើរ នោះសូមអោយយើងចេះបើកដួងចិត្ត និងចេះទទួលនូវអំណោយទានទាំងអស់ដែលព្រះជាម្ចាស់ប្រោសប្រទានអោយ ។

បងប្អូនជាទីស្រលាញ់! ខែនេះចូលឆ្នាំថ្មីនៃគ្រីស្តសករាជ " ២០០៤ "

តទៅទំព័រទី ៤



បងស្រី អេមា (រូបកណ្តាល ) រួមជាមួយលោកអភិបាល គីគេ និង ក្រុមបងស្រីឧបការៈគុណ

# មរណៈភាពបងស្រីអេមា រាលសាលី

"ក្រុមគ្រួសារឧបការគុណ"

បងស្រីអេមា រាលសាលី ជាបងស្រីក្រុមគ្រួសារឧបការគុណ បានទទួលមរណៈភាពកាលពីថ្ងៃ ចន្ទ័ វេលាម៉ោង ៨យប់ ដោយរោគាពាធ បងស្រីមានស្រុកកំណើតនៅក្នុងខេត្តបាត់ដំបង ។ បងស្រីកើតនៅថ្ងៃទី ១៧ ខែវិច្ឆកា ឆ្នាំ ១៩២៩ ហើយបានចូលនៅក្នុងក្រុមអ្នកបួសនៅឆ្នាំ ១៩៤៨។ បងស្រី បានធ្វើសច្ចាលើកទី១ នៅថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ១៩៥០ ហើយសច្ចាលើកទីពីរនៅថ្ងៃទី ១៩ ខែមិនា ឆ្នាំ ១៩៥៦ ។

តទៅទំព័រទី៥

# ព្រះយេស៊ូសំដែងឋានៈព្រះអង្គ : សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ក្នុងចំណោមអ្នកទន់ខ្សោយ



*កុមារីស្រីនាង និង កុមារីនៃមណ្ឌលអារូប៉េ*

យុទ្ធីជាក្មេងស្រីតូចអាយុ ៩ឆ្នាំ ដែលទើបតែទទួលការវះកាត់ជើងទាំងពីររបស់នាងដោយសារជម្ងឺស្វិតដៃជើង។ នាងយំយ៉ាងខ្លាំង ហើយនៅក្បែរនាងមានក្មេងស្រីម្នាក់ក្នុងទឹកមុខស្រស់ស្រាយនិងនិយាយដោយជំនឿចិត្តៈ

"តើលោកជាឪពុករបស់យុទ្ធី?តើលោកអាចធ្វើជាឪពុកខ្ញុំដែរបានឬទេ?"

ខ្ញុំឆ្លើយថា "បាន"

"អីចឹងថ្ងៃក្រោយសូមផ្ញើស្កគ្រាប់អោយខ្ញុំខ្លះ"។

"មិនអីទេខ្ញុំនឹងយកមក។ តែបើក្តួយចង់ធ្វើជាកូនរបស់ខ្ញុំ ហើយចង់ចូលក្នុងបេះដូងរបស់ខ្ញុំដូចយុទ្ធី ក្តួយត្រូវចូលក្នុងម៉ាស៊ីនថតរបស់ខ្ញុំសិន ដើម្បីអោយខ្ញុំអាចថតរូបក្តួយបាន។"

នាងលោតចូលក្នុងរទេះដែលនៅក្បែរគ្រែរបស់នាងយ៉ាងលឿន ហើយបង្វិលទៅក្នុងសួនច្បារមន្ទីរពេទ្យ។ ស្រីនាង ត្រូវដាច់ម្រាមជើងដោយសារគ្រាប់មីន។ ប៉ុន្តែនាងពោរពេញទៅដោយកំលាំងចិត្តនិងជីវិត។ ស្រីនាងជួយយុទ្ធី ជាច្រើននៅពេលលំបាកបន្ទាប់ពីការវះកាត់។ ស្រីនាង និងយុទ្ធីក្លាយជាមិត្តល្អក្នុងពេលទុក្ខសោក តែប្រកបដោយក្តីសង្ឃឹម។

ពីរបីសប្តាហ៍ក្រោយស្រីនាងត្រឡប់ទៅផ្ទះនាងវិញនៅព្រៃធំស្រុកបាវិល។ ហើយយើងព្យាយាមទៅលេងនាង។ ពេលនោះជារដូវភ្លៀង ផ្លូវចូលមានការលំបាក ដូច្នេះយើងមិនអាចទៅ មើលនាងបាន។ យើងដឹងថាវាជាការពិបាកដើម្បី ទៅដល់ភូមិរបស់នាង ហើយយើងក៏ដឹងដែរថា ប្រជាជនក៏មានការលំបាកក្នុងការធ្វើដំណើរ និងដឹកជញ្ជូនផលិតផលរបស់ពួកគេទៅកាន់ទីផ្សារ និងក្នុងការទាក់ទងជាមួយសង្គមខាងក្រៅដែរ។ នៅទីបញ្ចប់គឺបន្ទាប់ពីដំណើរលើកទីបី យើងអាចទៅដល់ផ្ទះរបស់នាង វាគឺជាខ្ទមតូចដ៏កំសត់មួយ។ ទាំងភូមិទាំងផ្លូវពិបាកខ្លាំងណាស់។ យើងឃើញថាភូមិនោះពោរពេញទៅដោយគ្រាប់មីន។ គ្មានសាលារៀន ហើយកុមារជាច្រើននៅក្នុងភូមិគ្មានការអប់រំ។ ពេលរដូវប្រាំងពួកគេមានបញ្ហាទឹក ដោយសារគ្មានប្រព័ន្ធផ្ទុកទឹកនៅពេលរដូវវស្សា។

តើយើងដឹងរឿងទាំងនេះដោយរបៀបណា? អរគុណស្រីនាង! ថ្ងៃនេះយើងស្គាល់ភូមិរបស់នាង ហើយយើងអាចរួមគ្នាជួយដោះស្រាយបញ្ហារបស់ភូមិៈ ការដោះមីន ការអប់រំកុមារ ប្រព័ន្ធធារាសាស្ត្រ ផ្តល់ផ្ទះដល់ជនក្រីក្រ។

ដោយសារយើងស្គាល់នាងតូចស្រីនាងជិតស្និទ្ធ ទើបយើងអាចដឹងនូវតម្រូវការរបស់ប្រជាជននៅភូមិរបស់នាង។ ស្រីនាងដូចជាព្រះកុមារយេស៊ូ ដែលបានប្រសូតនៅភូមិក្រីក្របេថ្លេហិមដែរ ដែលប្រៀនប្រដៅ ពួកយើងអំពីសេចក្តី ស្រឡាញ់របស់ព្រះជាម្ចាស់។ ដូចគ្នានេះដែរ យើងដឹងថាតើព្រះជាម្ចាស់គង់ក្នុងចំណោមពួកយើងយ៉ាងដូចម្តេច។ នាងជាក្មេងស្រីតូច មកពីភូមិដ៏ក្រីក្រមួយនៃប្រទេសកម្ពុជាដែលបង្រៀនយើងអោយយកចិត្តទុកដាក់ចំពោះអ្នកតូចតាច អោយចេះស្រឡាញ់អ្នកទុគិត បង្រៀនយើងអោយស្គាល់អំពីតម្រូវការរបស់អ្នកក្រ។ ព្រះយេស៊ូជាព្រះឱរសបង្រៀនយើងអោយ ស្វែងរកព្រះជាម្ចាស់នៅក្នុង ចំណោម អ្នកទន់ខ្សោយនៅក្នុងសង្គម។ យើងសូមអរព្រះគុណព្រះជាម្ចាស់ ចំពោះការបង្ហាញរបស់ព្រះអង្គ។ កុមារយេស៊ូប្រៀនប្រដៅយើងអំពីសេចក្តីស្រឡាញ់របស់ ព្រះជាម្ចាស់ចំពោះអ្នកតូចតាច និងអរគុណ ស្រីនាងព្រោះព្រះជាម្ចាស់ត្រាស់ហៅយើង អោយចេះស្រឡាញ់អ្នកតូចទាប។ នៅក្នុងការសំដែងឋានៈរបស់ព្រះយេស៊ូ ព្រះជាម្ចាស់បង្ហាញអោយពិភពលោក ឃើញមាគ៌ារបស់ព្រះអង្គ នៅក្នុង



*កុមារី យុទ្ធី និង កុមារីស្រីនាង*

ភាពទន់ខ្សោយ របស់កុមារ។ សព្វថ្ងៃនៅកម្ពុជាពោរពេញទៅ ដោយកុមារដូចស្រីនាង យុទ្ធី និងកុមារ ផ្សេងៗទៀត។ យើងឮការត្រាស់ហៅរបស់ព្រះជាម្ចាស់អោយស្រឡាញ់អ្នកតោកយ៉ាក។ អរគុណព្រះជាម្ចាស់ ដែលត្រាស់ហៅយើង អោយទទួលសេចក្តី ស្រឡាញ់របស់ព្រះអង្គនៅ ក្នុងវត្តមានរបស់អ្នកទន់ខ្សោយ។

*លោកអភិបាល គីគេ ហ្វីការេដូ*

# សិក្ខាសាលាគ្រូអប់រំជំនឿមនុស្សពេញវ័យ



*សិក្ខាកាមដែលចូលរួមក្នុងអង្គសិក្ខាសាលា*

កាលពីថ្ងៃទី ៨ ខែធ្នូ រហូលដល់ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០០៣ មានសិក្ខាសាលាទូទាំងប្រទេសមួយនៅក្រុងព្រះសីហនុ គឺស្ថិនៅក្នុងព្រះវិហារកំពង់សោម ដែលមានសិក្ខាកាមចំនួន ៥០នាក់មកពីភូមិភាគទាំងបី ភូមិភាគភ្នំពេញ ភូមិភាគបាត់ដំបង ភូមិភាគកំពង់ចាម)។ សិក្ខាសាលានេះបានរិះគិតអំពីប្រធានបទ "ការអប់រំមនុស្សពេញវ័យ " ដោយសង្កត់ធ្ងន់ទៅលើអគ្គសញ្ញាជ្រមុជទឹក ។ នៅក្នុងសិក្ខាសាលានេះគេក៏បានរំលឹកឡើងវិញផងដែរ អំពីវិធីសាស្ត្រ និងគរុកោសល្យសំរាប់អ្នកណែនាំជំនឿ។ នៅថ្ងៃទី ១នៃអង្គសិក្ខាសាលា សិក្ខាកាមទាំងអស់បានធ្វើសេចក្តីរាយការណ៍ជាសង្ខេបអំពីចំនួនអ្នកស្វែងយល់នៅតាមព្រះសហគមន៍នីមួយៗក្នុងឆ្នាំ ២០០៣ និងចែកបទសោធន៍គ្នាទៅវិញទៅមក។ នៅថ្ងៃនោះក៏បានរំលឹកផងដែរ អំពីគោលបំណងរបស់អ្នកណែនាំជំនឿ ដោយពាក្យបីថា "ចំណេះ ជំនឿ និងការអនុវត្តន៍"។ នៅថ្ងៃទី ២ អង្គសិក្ខាសាលាបានពិភាក្សាទៅលើអគ្គសញ្ញាទាំងបួន "អគ្គសញ្ញាជ្រមុជទឹក អរព្រះគុណព្រះជាម្ចាស់ លាបថ្វាស់ និងអគ្គសញ្ញាលើកលែងទោស"។ លោកអភិបាលអេមីលបានពន្យល់បញ្ជាក់អំពី អគ្គសញ្ញាជ្រមុជទឹក ដោយភ្ជាប់ជាមួយអត្ថន័យនៃបុណ្យចំលង។នៅថ្ងៃទី ៣ និង ទី ៤ បានពិភាក្សា ពីធីផ្សេងៗក្នុងពេលអប់រំជំនឿ ធ្វើយ៉ាងណាដើម្បីអោយអ្នកទទួលអប់រំមាន ការចាប់អារម្មណ៍ គឺ មិនគ្រាន់តែនិយាយទ្រឹស្តីទេ ត្រូវមានការអនុវត្តន៍ជាក់ស្តែងផងដែរ។

យើងសង្កេតឃើញថាក្នុងរយៈពេលនេះ អង្គសិក្ខាសាលាបានប្រព្រិត្តទៅក្នុងបរិយាកាលដ៏សប្បាយរីករាយ ។ សិក្ខាសាលានេះណែនាំដោយលោកបូជាចារ្យ ប៊ុងសូដឺនិង បងស្រីហ្ស៊ីប៊ែក។ នៅពេលបញ្ចប់សិក្ខាកាមទាំងអស់ទទួលបានបទពិសោធន៍ពីគ្នាទៅវិញទៅមក ដើម្បីយកទៅចែករំលែកដល់បងប្អូនដែលមានបំណង់ចង់ស្គាល់ពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។ ***អ្នកនាំសារ***

---

*តមកពីទំព័រទី៨*

អង្គការបានជួយបង់ថ្លៃសាលា សំល្បេកបំពាក់ សំភារៈសិក្សា និង បង់ថ្លៃខាត់បង់ចំពោះគ្រួសារដែល បានអោយកូនទៅរៀនដែលមិនបានជួយរក ប្រាក់ចំណូល។

**៥- ការថែរក្សាកុមារដែលស្ថិតក្នុងភាពគ្រោះថ្នាក់**

**៦- ការថៃទាំកុមារដែលជួបញ្ហោះ** ការផ្តល់ចំណីអាហារ និងថ្នាំពេទ្យ បំប៉នម្តាយដែលគ្មានទឹកដោះបំបៅកូន, អប់រំដល់ម្តាយពីការរៀបចំគំរោងក្នុងគ្រួសារ និង អនាម័យ ,...) ចែកម្ហូបអាហារបីដងក្នុងមួយអាទិត្យមានក្មេងចំនួន ២០នាក់ដែលទទួលការ ថែរទាំក្នុងមួយថ្ងៃដែលមកពីគ្រប់សង្កាត់ទាំងអស់ ។

**៧-ការឧបត្ថម្ភដល់គ្រួសារកើតអេដស៍** : អង្គការបានយកកូនរបស់គេមកអោយរៀន

-ជួយជាអង្ករជំនួសនូវការបាត់បង់កំលាំងដើម្បីរកចិញ្ចឹមជីវិតដោយរើសអេតចាយនៅលើគំនរសំរាមតាមថ្ងៃដែលកូនរបស់គេបានមករៀន។ អោយខ្ចីប្រាក់ដោយអោយការងារធ្វើបណ្តោះអាសន្ននៅក្នុងអង្គការ។

-អោយគេចាប់ផ្តើមការងារមួយថ្មីក្រៅពីគំនសំរាម។

-បង្រៀនអក្ខរកម្មដល់ម្តាយដែលនៅវ័យក្មេង។

**៨-កម្មវិធីទទួលនិងគ្រប់គ្រងកុមាររបស់យើង:** ស្តាប់បញ្ហាដែលមានក្នុងក្រុមកុមារ ទទួលកុមារពីគំនរសំរាម ការណែនាំ បង្កើតជាក្រុមកាយរិទ្ធ សួរសុខទុក្ខកុមារមានជំងឺនិងកំព្រា និងកសាងលំនៅដ្ឋានថ្មីអោយគេ។ ***អ្នកនាំសារ***

**អ្នកនាំសារ**

**ក្រុមនិពន្ធ**
គឹម រតនា, គឹម សំអាត
**រូបភាព :** គុយវិន , Amadeus
**កុំព្យូទ័រ :** លី សុវណ្ណា
ការិល័យផ្សព្វផ្សាយពតិមានព្រះសហគមន៍កាតូលិក
Nº 787, Monivong Blvd,
Phnom Penh-CAMBODIA
Tel/Fax : (855) 23 726 197
E-mail : cscmediacenter@ bigfoot.com
<u>អភិបាលគ្រប់គ្រង</u>
លោកអភិបាល អេមីល ដេតម្ប
<u>អគ្គនាយក</u>
លោកបូជាចារ្យ អូមែរ ហ្សីរ៉ាល់ដូ

# យើងត្រូវនឹកដល់គោលដៅជានិច្ច

***តមកពីទំព័រ ទី ១***

រដូវរង់ចាំបានជួយក្នុងព្រះសហគមន៍រៀបចំផ្លូវ រៀបចំចិត្តគំនិតទទួលដើម្បី ព្រះកុមារយេស៊ូ ដែលនិងយាងមកស្ថិត ក្នុងដួងចិត្តរបស់យើង ម្នាក់ៗ។ នៅខែ មករា នេះជាឱកាសដ៏ល្អមួយ សំរាប់យើងកែប្រែចិត្តគំនិតជាថ្មី ព្រមទាំង អរព្រះគុណព្រះជាម្ចាស់ ដែលបានផ្តល់ អំណោយទានអោយយើង និងសូមទ្រង់ផ្តល់ ជំនឿអោយយើងថែមទៀត។

ក្រោយថ្ងៃបុណ្យណូអែលព្រះសហគមន៍ធ្វើពិធី (Epiphanie) គោរពព្រះជាម្ចាស់ សំដែងព្រះអង្គអោយមនុស្សលោកស្គាល់គឺថា: ព្រះជាម្ចាស់យាងមកបំភ្លឺជីវិតរបស់យើង និងមនុស្សលោកទាំងអស់។ ដូច្នេះហើយបាន ជាព្រះសហគមន៍សូមអញ្ជើញយើងអោយ យកពេលវេលាស្ងឹងស្ងាធ ដើម្បីរិះគិតពីជីវិត របស់ព្រះកុមារយេស៊ូក្នុងវ័យជំទង់ ។ក្នុងខែ នេះព្រឹត្តិប័ត្រ*អ្នកនាំសារ*យើងសូមបងប្អូន រិះគិត ពីប្អូនវ័យជំទង់នៅក្នុងវ័យនេះគេចេះ តែចង់ធ្វើ អ្វី តាមតែទំនើងចិត្តរបស់គេ។ បើយើងសង្កេតមើលទៅក្នុងសង្គមសព្វថ្ងៃ ក៏ដូចជានៅតាមព្រះសហគន៏របស់យើងដែរគឺ ព្រះសហគមន៍ចាប់អារម្មណ៍អំពីការអប់រំក្មេង ជំទង់ និងយុវជនយុវនារីជាច្រើន។ បើយើងរិះគិតពីជីវិតរបស់ពួកគេ មានឧបសគ្គជាច្រើន ដែលជាពិសេសសំរាប់សង្គមយើងសព្វថ្ងៃ ពោរពេញទៅដោយការរីកចំរើនជាច្រើន។ ក្នុងជីវិតរបស់យើងម្នាក់ៗយើងសុទ្ធតែបាន ទទួលនូវអ្វី មួយដែលដឹកនាំយើងទៅកាន់ គោលដៅដែលជាបំណងប្រាថ្នារបស់យើង។

ឧទាហរណ៏ៈក្នុងរឿងពួកហោរាចារ្យ ក្នុងព្រះគម្ពីរដំណឹងល្អ តែងដោយលោក ម៉ាថាយជំពូក ២ ពួកហោរាចារ្យបានឃើញ ផ្កាយ ហើយពួកគេនាំគ្នាធ្វើដំណើរទៅជួប ព្រះជាម្ចាស់ " ព្រះកុមារយេស៊ូ ដែលផ្ទុំក្នុង ស្នូកសត្វ " នោះពិតជាព្រះអំណោយទានមួយ មែន។ ការដើរតាមពន្លឺផ្កាយវាពុំមែនជាការ ងាយទេ គេត្រូវធ្វើដំណើរយ៉ាងវែងឆ្ងាយមាន ឧបសគ្គជាច្រើន តែពួកគេនៅតែទៅមុខជា និច្ចមិនរុញរាសោះឡើយ។ ចំនុចនេះមាន សារៈសំខាន់ណាស់ចំពោះជិវិតរបស់យើង ម្នាក់ៗ ដែលកំពុងស្វែងរកអ្វីមួយ កំពុងទទួល ការអប់រំ ឬកំពុងបំពេញកិច្ចការអ្វីមួយ។ យើងមិនត្រូវបណ្តោយខ្លួនអោយភ្លេចនឹក គិតពីបំណងប្រាថ្នារបស់ខ្លួននោះឡើយ។ ប្រសិនបើយើងចេះតែបណ្តោយខ្លួន ទៅតាម ការ នឹកឃើញ ឬទន់ជ្រាយតាមការលំបាកការ



*ការជួយយុវជនរិះគិតពីតំលៃជីវិតរបស់ខ្លួន*

ហត់នឿយឬឧបសគ្គផ្សេងៗដែលរារាំងផ្លូវ នោះយើងពិតជាទទួលបរាជ័យ ហើយមិន អាចសំរេចបំណងប្រាថ្នារបស់យើងជាក់ជាមិន ខាន ។ ផ្ទុយទៅវិញការលំបាក ការនឿយហត់ ឬឧបសគ្គនោះ ជាបញ្ហាដែលតែងតែកើត ឡើងក្នុងជីវិតយើងគ្រប់គ្នា។ អ្វីដែលសំខាន់ គឺយើងត្រូវចងចាំជានិច្ចថា "ព្រះជាម្ចាស់ បង្កើតយើង និង ប្រទានអោយយើងមាន ប្រាជ្ញាចេះដោះស្រាយរាល់បញ្ហាស្មុគស្មាញ និង ប្រទានអោយយើងឆ្លងកាត់នូវរាល់ការ លំបាកផ្សេង ៗ ដោយអោយយើងហ៊ានសំរេច ចិត្តដោយខ្លួនឯង ដែលមានព្រះវិញ្ញាណ ជួយណែនាំនិងផ្តល់កំលាំងអោយយើងជានិច្ច សូមកុំខ្លាចអ្វីឡើយ! ចូរបំពេញគ្រប់កិច្ចការ ដែលត្រូវធ្វើហើយបំពេញកិច្ចការដែលអ្នកបាន គ្រោងទុកនោះតាមបំណងប្រាថ្នាដោយ ក្តីស្រឡាញ់ និងដោយក្តីស្មោះត្រង់នោះទៅ ព្រះជាម្ចាស់នឹងជួយបំពេញបន្ថែមនូវ កង្វះខាតរបស់យើងអោយបានកាន់តែ ប្រសើរលើសពីក្តីត្រូវការរបស់យើងទៅ ទៀត។ សូមកុំខ្លាចអ្វីឡើយព្រះជាម្ចាស់គង់ នៅជាមួយយើងជានិច្ច។

***បូជាចារ្យ អ៊ុន សុន***



*សិស្សសាលាសន្តហ្វ្រង់ស័រសាវីយេ (ចំការឡេង)*

*តពីទំព័រទី ១*



*បងស្រី អេមា ស្បៀកពាក់ជាដូនជី*

-ឆ្នាំ១៩៥០-១៩៦៨ បងស្រីបានបំពេញបេសកកម្មនៅនៅព្រះវិហារព្រះមាតាភ្នំពេញ ។
-ឆ្នាំ១៩៦៩-១៩៧០ បងស្រីត្រូវបានចាត់អោយទៅធ្វើការជា គិលានុបដ្ឋាយិកានៅស្រុកជប់ ខេត្តកំពង់ចាម ។
-ឆ្នាំ១៩៧០-១៩៧២ បងស្រីត្រឡប់មកភ្នំពេញវិញ នៅទីនោះបងស្រីទទួលមើលថែរក្សាកុមារកំព្រា ។
-ឆ្នាំ១៩៧២-១៩៧៤ បងស្រីទទួលមុខងារជាគ្រូអប់រំជំនឿ នៅព្រះវិហារព្រះមាតាវិញ ។
-នៅខែ ឧសភា ១៩៧៤ដល់ខែ មករា ១៩៧៥ បងស្រីបានទៅសិក្សាបង្គ្រប់នៅប្រទេសបារាំង
-ខែមេសា ១៩៧៥ បងស្រីអេមាក៏ដូចបងស្រីទាំងអស់ដែរ ត្រូវបានគេជម្លៀសចេញពីភ្នំពេញជាមួយ និង ប្រជាជនឯទៀតៗ។ បងស្រីបានរស់នៅក្នុងរបបខ្មែរក្រហមអស់រយៈពេល៨ខែ ។
-ខែ ធ្នូ ១៩៧៥ បងស្រីអេមា និងបងស្រីផ្សេងទៀតបានទៅដល់ព្រៃនគរ ។
-ឆ្នាំ ១៩៧៦ បងស្រីអេមាបានធ្វើការនៅកន្លែងផលិតទូកន្ទេល នៅកងថៃ ។
-ឆ្នាំ១៩៨០-១៩៩០ បងស្រីអេមាបានធ្វើការនៅមណ្ឌលកុមារកំព្រារបស់រដ្ឋ នៅកងថៃ ។
-ថ្ងៃ១០ មករា ឆ្នាំ១៩៩១ បងស្រីបានត្រឡប់មកប្រទេសកម្ពុជាវិញជាមួយបងស្រីហ្សង់បាទីស្ត និងបងស្រីលីណា។
-ឆ្នាំ១៩៩២បងស្រីបានចូលបំរើក្នុង អនុគណៈកម្មការសង្គហៈនៅព្រះសហគមន៍បាត់ដំបង ។
-ខែ ឧសភា ២០០០បងស្រីបានធ្លាក់ខ្លួនឈឺ ហើយបានទៅសំរាកព្យាបាលនៅប្រទេសវៀតណាម។ បងស្រីបានបំពេញបេសកកម្មរបស់ខ្លួនដោយសេចក្តីស្រឡាញ់ ដោយចិត្តស្លូតបូត ក្លាហាន តស៊ូ អត់ធ្មត់ សុភាពរាបសារ ដោយដាក់ខ្លួនជាអ្នកក្រខ្សត់ក្នុងការបំរើព្រះជាម្ចាស់ និងព្រះសហគមន៍ តាមការអប់រំក្មេងៗ ការថែរក្សាអ្នកជំងឺ។ បងស្រីធ្វើការដោយចិត្តអត់ធ្មត់ រហូតដល់បងស្រីធ្លាក់ខ្លួនឈឺជាទម្ងន់ក៏បងស្រីមិនត្អូញត្អែសោះឡើយ។ បងស្រីថ្វាយនូវការឈឺចាប់ទាំងនោះទៅព្រះជាម្ចាស់ ជាមួយនិងទុក្ខលំបាកព្រះយេស៊ូ ដើម្បីព្រះសហគមន៍ និងដើម្បីបងប្អូនទាំងអស់ ដោយសេចក្តីស្រឡាញ់ ។

ដូច្នេះក្នុងនាមយើងជាគ្រីស្តបរិស័ទ ដែលជាមហាគ្រួសារតែមួយ សូមបងប្អូនរួមគ្នាអធិដ្ឋានសំរាប់វិញ្ញាណក្ខន្ធ័បង ស្រីដោយសេចក្តីសោកស្តាយ និងអគុណគ្រប់កិច្ចការដែលបងស្រីបានធ្វើចំពោះព្រះសហគមន៍ និងសំរាប់បងប្អូន យើងសូមព្រះជាម្ចាស់ទទួលព្រលឹងរបស់បងស្រីរួមជាមួយព្រះអង្គ នៅស្ថានបរមសុខផង។ សូមអោយយើងធ្វើកិច្ចការផ្សេងៗ ដោយចិត្តអត់ធ្មត់ដូចបងស្រីទាំងពេលសប្បាយនិងពេលឈឺចាប់ ។

*អ្នកនាំសារ*

## ដំណឹងពីមណ្ឌលវប្បធម៌កាតូលិក

មណ្ឌលវប្បធមកាតូលិកបានធ្វើសៀវភៅថ្មីសំរាប់ព្រះសហគមន៍សៀវភៅទាំងអស់មានចំណងជើងដូចតទៅ:

**-ដើមនៃគ្រីស្តសករាជ** :ជាសៀវភៅដែលសរសេរ អំពីព្រឹត្តិការណ៍នៃជីវិតរបស់ព្រះគ្រីស្ត តាំងពីព្រះអង្គចាប់កំណើតក្នុងផ្ទៃមាតា រហូតសោយទិវង្គត ដើម្បីសង្គ្រោះមនុស្សលោក ។

**-ដំណើរស្វែងរកពន្លឺ** : សៀវភៅនេះពន្យល់ដល់មហាជនដើម្បីអោយស្គាល់ពីសាសនានានាដែលមានក្នុងពិភពលោក ដោយសរសេរពន្យល់យ៉ាងល្អ ដោយប្រើពាក្យសាមញ្ញ ស្រួលអាន និងងាយយល់ ។

**-អធិដ្ឋានតាមមាលា(ផ្កា)**: គ្រីស្តបរិស័ទគ្រប់រូបចាំបាច់ត្រូវចេះរបៀបអធិដ្ឋានតាមមាលាជាមួយព្រឹត្តិការណ៍ទាំង២០។ សៀវភៅនេះ អាចជួយគ្រីស្តបរិស័ទអោយងាយស្រួលក្នុងការអធិដ្ឋានមាលា។ យើងមានសៀវភៅជាច្រើនទៀតស្តីពីការណ៍ផ្សេងៗ ក្នុងការអប់រំកុមារា កុមារី យុវជន និងមនុស្សពេញវ័យ អោយបានយល់ដឹងកាន់តែច្បាស់ពីគ្រីស្តសាសនា ។

បងប្អូនអាចទិញសៀវភៅនេះយកទៅអានខ្លួនឯងក៏បានដើម្បីរៀនម្នាក់ឯង ឬជាមួយក្រុមក៏បាន ឬធ្វើអំណោយអោយមិត្តភក្តិក្នុងពិធីផ្សេងក៏បានតាមត្រូវការ ។

បើអស់លោកអ្នក បងប្អូនត្រូវការជាវសៀវភៅទាំងអស់ខាងលើនេះ សូមទាក់ទងមកមណ្ឌលវប្បធម៍កាតូលិកកម្ពុជា (cccc) ។

**អាស័យដ្ឋានៈ ផ្ទះ១០១ សង្កាត់ បឹងត្របែក**
**ខ័ណ្ឌចំការមន ភ្នំពេញ**
**ទូរស័ព្ទ : ០២៣ ២១១ ២៩៣**
**E-mail : cccc@catholiccambodia.org**









# ក្រុមអេម៉ាណូអែល !



*យុវជនសមាជិកក្រុមអេម៉ាណូអែល និង បូជាចារ្យដែលជួយណែនាំ*

យើងខ្ញុំមានអំណរសប្បាយ សូមជំរាបបងប្អូនខ្លះៗអំពីក្រុមអេម៉ាណូអែល ។ អេម៉ាណូអែលជាក្រុមមួយដែលត្រូវបានបង្កើតឡើងក្នុងអំឡុងពេលបី រឺ បួនឆ្នាំថ្មីៗនេះ។ គោលបំណងរបស់ក្រុមអេម៉ាណូអែលគឺញ៉ាំងអោយយើងខ្ញុំ ដែលជាសមាជិកក្រុមរួបរួមគ្នារិះគិតអំពី បញ្ហាជីវិត រួមមានដូចជាសេចក្តីស្រឡាញ់ អំណរសប្បាយ ទុក្ខលំបាកសេរីភាព សោភ័ណ្ឌភាពពិភពលោក វត្តមាន-របស់ព្រះជាម្ចាស់ ក្នុងជីវិតរបស់ពួកយើងម្នាក់ៗ រំលឹកជីវិតក្នុងអតីតកាល ... ។ល។ ទាំងអស់នេះជាប្រធានបទខ្លះៗ ដែលយើងធ្លាប់បានរិះគិត និង បន្តរិះគិតជាមួយគ្នាក្នុងក្រុមអេម៉ាណូអែល ។

អ្នកដែលចូលជាសមាជិកក្រុមអេម៉ាណូអែល គឺតំរូវអោយជួបជុំគ្នាដើម្បីពិភាក្សារិះគិតបញ្ហាជីវិត និងចែករំលែកបទពិសោធន៍ជីវិតអោយគ្នាទៅវិញទៅមក ជារៀងរាល់ ១ខែម្តង។ ហើយក្នុងពេលថ្មីៗនេះដែរក្រុមយើងមានការជួបជុំគ្នានៅទេវវិទ្យាល័យភ្នំពេញ ដើម្បីរិះគិតអំពី ប្រធានបទ មួយគឺ "ទុក្ខលំបាក"។ សកម្មភាពនៃការប្រជុំប្រព្រឹត្តទៅចាប់ពី ថ្ងៃទី ០៦-០៧ ខែធ្នូ ឆ្នាំ ២០០៣ ដែលមាន ការចូលរួមពីបណ្តាយុវជនដែលជាសមាជិកក្រុមអេម៉ាណូអែល ប្រមាណជាម្ភៃនាក់ដែលដឹកនាំអង្គប្រជុំដោយ លោកឪពុក ប៊្រុយណូ និងមានការចូលរួម ពីសំណាក់អស់លោកបូជាចារ្យផ្សេងៗទៀត ដូចជា លោក ស៊ុន លោក ទីន និង លោក ម៉ារីអូ។

យើងបានចាប់ផ្តើមអង្គប្រជុំដោយមានបទចំរៀងក្រុមអេម៉ាណូអែលខ្លះៗ ដើម្បីច្រៀងកំដរបរិយាកាស និង ពិភាក្សាចែកបទពិសោធន៍គ្នា ដោយត្រង់ទៅត្រង់មក ឥតលាក់លៀម និង ឥតមានភាពអៀនខ្មាស់ឡើយ ។ លុះលាចឡើង យើងបានប្រារព្ធពិធីនមសិកាព្រះកាយព្រះគ្រីស្តជាមួយគ្នា ដោយស្ងឹងស្ងាធ និង ផ្ញើទុក្ខលំបាករបស់ខ្លួនទៅក្នុងព្រះហស្តរបស់ព្រះយេស៊ូគ្រីស្ត បន្ទាប់មកយើងបានទស្សនាខ្សែភាពយន្តខ្នាតធំមួយអំពីរឿង "គុកទួលស្លែង" ក្នុងពេលទស្សនាម្នាក់ៗដូចជាផ្តោតអារម្មណ៍ទៅលើសាច់រឿងនេះយ៉ាងខ្លាំង លុះព្រឹកឡើង ថ្ងៃអាទិត្យក្រុមរបស់យើងបានទៅចូលរួម ថ្វាយអភិបូជានៅព្រះសហគមន៍បឹងទំពុន ក្រោយមកយើងបានបង្ហាញខ្លួនអោយបងប្អូនគ្រីស្តបរិស័ទនៅទីនោះស្គាល់ និង មានការសំណេះសំណាល គ្នាលេងព្រមទាំងមានការថតរូបរួមគ្នា ក្រោយមកយើងត្រលប់មកទីតាំងប្រជុំវិញ និង បន្តរិះគិតអំពីសាច់រឿងដែលឆ្លុះបញ្ចាំងពីទុក្ខលំបាករបស់ប្រជារាស្ត្រខ្មែរ នៅសម័យប៉ុលពតរួចមកប្រៀបធៀបនឹងទុក្ខលំបាករបស់យើងជាគ្រីស្តបរិស័ទនាបច្ចុប្បន្ននេះ គ្រប់គ្នាបានបញ្ចេញ មតិយោបល់របស់ខ្លួនដោយក្តីសោមនស្សរីករាយ រហូតដល់ម៉ោងបួនរសៀល ទើបអង្គប្រជុំត្រូវបានបញ្ចប់ តែមុនពេលបញ្ចប់យើងបានពិភាក្សាវាយតំលៃទៅលើអង្គប្រជុំ និងមានសំណូមពរខ្លះៗ និង រិះគិតពីប្រធានបទថ្មីៗ ក៏ដូចជាទីតាំង ប្រជុំសំរាប់កាសពេលក្រោយៗទៀត ។

ថ្វីដ្បិតការប្រជុំនេះមានរយៈពេលខ្លីក៏ពិតមែន ប៉ុន្តែសកម្មភាពនៃការប្រជុំគឺមានភាពរស់រវើកតែម្តង ហើយក្នុងនាមពួកយើងជាក្រុមអេម៉ាណូអែល យើងខ្ញុំមានអំណរសប្បាយ ព្រមទាំងសូមអរគុណលោកឪពុក ទាំងអស់ ដែលបានផ្តើមគំនិតក្នុងការបង្កើតក្រុមអេម៉ាណូអែលនេះឡើង ព្រោះថាការចូលរួម ក្នុងក្រុមអេម៉ាណូអែលយើងមិនត្រឹមតែស្គាល់មិត្តថ្មីៗដែលអញ្ជើញមកពីព្រះសហគមន៍ផ្សេងៗ ដែលមាននៅប្រទេសកម្ពុជាទេ ប៉ុន្តែយើងថែមទាំងទទួលបាននូវបទពិសោធន៍នៃជីវិតដ៏ល្អៗពីបណ្តាមិត្តដែលជាសមាជិកក្រុម និង ជួយយើងខ្ញុំអោយចេះរិះគិត អោយកាន់តែស៊ីជំរៅខ្លាំងឡើងអំពីបញ្ហាជីវិត ចេះរិះគិតពីគំរោងជីវិតនាពេលអនាគត ជាពិសេសគឺជួយអោយយើងខ្ញុំចេះបំរើបងប្អូនឯទៀតក្នុងព្រះសហគមន៍ ។ យើងខ្ញុំទាំងអស់សង្ឃឹមថា នឹងមានយុវជនជាច្រើនដែលចង់ចូលក្នុងក្រុមអេម៉ាណូអែល។

*វិសាល ខៀន*

# វិធីទាំង៧ក្នុងការអធិដ្ឋាន

ដកស្រង់ចេញពីវីដេអូដែលមានឈ្មោះថា seven circle of prayer ដែលចេញផ្សាយដោយ CAHAYA SUARA RESOURCE CENTRE ពីទីក្រុងកូឡាឡាំពួរ ហើយបកប្រែជាភាសាខ្មែរ ដោយបងស្រី សង្វាត នឹង បងស្រី ថារីន ក្រុមគ្រួសារស្រលាញ់ព្រះឈើឆ្កាង។ **តពីលេខមុន**

## ៣- ការមើល

នៅ២ជំហានបន្ទាប់ទៀតនេះ រៀបរាប់អំពីភាពប្រែប្រួលនៅពេលអធិដ្ឋាន។ ដំបូងភាពប្រែប្រួលវាប្រព្រឹត្តទៅតាមអ្វី១ ដែលយើង មើលឃើញនៅជុំវិញខ្លួន។ បងប្អូននឹងយល់កាន់តែច្បាស់ឡើង ពីការប្រព្រឹត្តទៅរបស់អ្វីទាំងអស់ដែលមាននៅជុំវិញបងប្អូន។ ក្នុងការរស់នៅប្រចាំថ្ងៃសូម បងប្អូនរកកន្លែងមួយហើយ នៅស្ងៀមស្ងាត់វាអាចជួយបងប្អូននឹកឃើញឡើងវិញនូវអ្វីដែលបានកន្លងហួសទៅនឹងបញ្ហាដែលកើតមានឡើងនៅក្នុងជីវិតរបស់បងប្អូនដដែល១នោះ។ បងប្អូនអាចរកកន្លែងដើម្បីនៅស្ងៀមស្ងាត់ជាប្រចាំ វានឹងជួយសំរួលអោយបងប្អូនអាចកាត់បន្ថយសំលេងពីខាងក្រៅ និងនឹកឃើញនូវអ្វី១ ដែលបងប្អូនបានឃើញពីមុនមក។ បងប្អូននឹងមើញឃើញនូវមូលហេតុដែលបណ្តាល អោយមានភាពតានតឹង និងទុក្ខព្រួយ ភាពឆាប់ទទួលការឈឺចាប់និងការអស់សង្ឃឹម។ តាមរយៈការស្ងៀមស្ងាត់និងមានទីកន្លែងល្អបងប្អូន នឹងបានយល់កាន់តែច្បាស់ឡើងពីពិភពលោក និងអ្វី១ដែលមាននៅជុំវិញបងប្អូន ដូចជាលើផែនដីមានពេលយប់នឹងពេលថ្ងៃ មានរដូវរងារ និងរដូវក្តៅ ។

សំលេងបក្សាបក្សីជាសំលេងមួយធម្មតាតែអាចជួយអោយបងប្អូនមានអំណរសប្បាយដែរ។ ប៉ុន្តែសូមកត់ចំនាំថាអ្វី១ខាងលើនេះមិនទាន់គ្រប់គ្រាន់ទេ ។ ប្រសិនបើបងប្អូនចង់ អធិដ្ឋានយ៉ាងពិតប្រាកដ ប្រសិនបើបងប្អូនកំពុង ស្វែងរកព្រះជាម្ចាស់តាមរយៈការអធិដ្ឋានបង ប្អូនចាំបាច់ត្រូវពិរ




ណាអោយបានស៊ីជំរៅនូវអ្វីដែលបងប្អូនបានជួបនិងបានឃើញកន្លងមក។

ពេលស្ងៀមស្ងាត់លើកក្រោយ សូមសាកល្បងរំលឹងឡើងវិញនូវអ្វីដែលបងងប្អូនបានឃើញកន្លងមក ។ សុំអង្វរព្រះជាម្ចាស់ សូមព្រះអង្គបើកភ្នែកនៃដួងចិត្តរបស់បងប្អូន សូមព្រះអង្គជួយយើងអោយចេះទទួលយកនូវអ្វី១ដែលនៅជុំវិញខ្លួនយើង។ ភ្នែករបស់បងប្អូន បើករហូត ហើយខួក្បាលរបស់បងប្អូន ទទួលផ្ទុកច្រើនជាងអ្វីដែលបងប្អូនចងចាំទៅទៀត ។

យើងទាំងអស់គ្នាភាគច្រើនជាប់រវល់នឹងការងារជានិច្ច ហើយការចាប់អារម្មណ៏របស់យើងបានតែផ្នែកមួយតូចដែលខ្លួនបានមើលឃើញប៉ុណ្ណេះ ។ វិញ្ញាណយើងមិនសំរាក់ទេ។ យើងត្រូវការធ្វើអោយអ្វីផ្សេង១ទៀតមានដំណើរការ។ ប៉ុន្តែសូមកុំធ្វើអោយពតិមានផ្សេង១ទៀតមានការបាត់បង់ឡើយ ទុកមួយកន្លែងកុំទាន់គិតដល់វា។ ភ្នែករបស់បងប្អូនបើករហូតហើយ ខួក្បាលរបស់បងប្អូនទទួលផ្ទុករហូតតែអ្វី១ទាំងនោះ យើងមិនបានប្រុងប្រយ័ត្នចងចាំទុកឡើយ។ ដូច្នេះសុំអង្វរព្រះជាម្ចាស់សូមព្រះអង្គបើកចិត្តគំនិតរបស់បងប្អូន សូមព្រះជាម្ចាស់ជួយយើងអោយយល់ពីដំណើរជីវិតរបស់ខ្លួន។ សូមព្រះជាម្ចាស់ជួយយើងអោយ ចេះមើលឃើញភាពអស្ចារ្យ និងភាពទន់ខ្សោយរបស់មនុស្ស សូមព្រះជាម្ចាស់ជួយយើងអោយស្គាល់ខ្លួនឯង និងអ្នកដទៃ។ ពេលបងប្អូនអធិដ្ឋានដូច្នេះ ជួនកាលធ្វើអោយទទួលបានភាពស្ងប់ស្ងាត់ វីក៏អាចធ្វើអោយរកឃើញគំនិតដែលមានសារៈសំខាន់ វីក៏ភ្លេចអស់នូវទុក្ខកង្វល់តាមរយៈការអធិដ្ឋាន។ ប្រហែលជាបងប្អូនមានគំនិតមិនបានការជាច្រើនដែលកំពុងអណ្តែតនៅជុំវិញគំនិតរបស់បងប្អូន ដើម្បីរំលឹកបងប្អូនអោយនឹកដល់អ្វីមួយ វីអ្នកណាម្នាក់ដែលត្រូវការអោយបងប្អូនអធិដ្ឋានអោយគេ។ សូមកុំបោះគំនិតនេះអោយសោះ។ ការគិតនេះនឹងជួយនាំអោយបងប្អូនចូលទៅជំហានបន្ទាប់នៃការអធិដ្ឋានទៀត។

ប៉ុន្តែជាដំបូងសូមអង្វរព្រះជាម្ចាស់រំលឹកយើងអោយនឹកឃើញនូវរាល់សេចក្តីស្រលាញ់និងអស់អ្នកដែលនៅជុំវិញខ្លួនយើងបន្ទាប់ មកទៀតសូមព្រះអង្គព្រះសណ្តាប់នូវរាល់ការគិតរបស់បងប្អូនដែលមាននៅក្នុងដួងចិត្ត។ នេះជារបៀបបន្ទាប់ទៀត។

**នៅមានត**



# អង្គការភាពញញឹម នៃកុមារ

អង្គការភាពញញឹមនៃកុមារ គឺជាអង្គការក្រៅរដ្ឋាភិបាលមួយដែលបានបង្កើតឡើង ក្នុងឆ្នាំ ១៩៩៣ ដោយគ្រីស្ទីន (Christain)និង Marie-France des Pallières។ ក្នុងបំណង ជួយដល់ក្មេង ដែលមិនបានទទួលការអប់រំដែលរស់នៅតាមគំនរសំរាមក្នុងក្រុងភ្នំពេញ។

## គោលដៅសង្គ្រោះកុមារចេញពីភាពវេទនា

អង្គការបានចូលរួមក្នុងគំរោងអភិវឌ្ឍន៍ កម្ពុជាដោយសហការជាមួយរដ្ឋអំណាចក្នុងតំបន់ដែលមានកិច្ចព្រមព្រៀងចុះហត្ថលេខា ដោយរដ្ឋមុន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា និងជាមួយការិយាល័យជនបរទេស។

នៅឆ្នាំ ២000 អង្គការភាពញញឹមនៃកុមារបានទទួល ការជួយឧបត្ថមពីប្រធានាបតីបារាំង និង The Human Rights Prize of the French Republic） នៅក្នុងពេលជាមួយគ្នានេះដែរ គ្រីស្ទីន ក៏បានទទួលគ្រឿងឥស្សរយស ក្រុងភ្នំពេញ និង លិខិតសរសើរពីសំណាក់ សម្តេចនាយករដ្ឋាមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ ។ នៅឆ្នាំ ២00១ ដោយគ្រីស្ទីន (Christain) និង Marie-France des Pallières បានទូលការថ្លែង អំណរគុណពីសំណាក់ព្រះករុណាសម្តេចព្រះបាទនរោត្តម សីហនុ និងព្រះរាជអគ្គមហេសី មុនីនាត សីហនុ នៅក្នុងឱកាសព្រះរាជដំណើរទស្សនៈកិច្ចរបស់ព្រះអង្គនៅក្នុងអង្គការនេះ។ នៅខែ មិថុនា ២00២ ភាពញញឹមនៃកុមារ ត្រូវបានទទួលស្គាល់ជាអង្គការមនុស្សធម៌មួយ។


*សិស្សបងមសិក្សានៅមណ្ឌលភាពញញឹមនៃកុមារ*

## សកម្មភាពទាំង ៨ របស់ អង្គការភាពញញឹម នៃកុមារ

១-**នៅលើគំនរសំរាមៈ**ជារៀងរាល់មោ ៉ង ៦,៣0 នាទីព្រឹក នៅតាមជំរុំដែលអង្គការបានសងសំរាប់ក្មេងៗនៅតាមគំនរ សំរាមទាំងអស់ បើកទទួលក្មេងៗមកសំអាតខ្លួន ចែកម្ហូបអាហារ ថែរក្សា និង បង្រៀនអក្ខរកម្ម។

២-**មណ្ឌលបន្តការសិក្សាៈ** អង្គការបានបើកថ្នាក់រៀនគ្រប់កំរិតទាំងអស់ចាប់ពី បឋមសិក្សារហូតដល់វិទ្យាល័យ ថ្នាក់ទី១២។ មានការប្រលង ២ដងក្នុងមួយឆ្នាំ។ ចាប់ពីឆ្នាំ ១៩៩៦ ក្មេងៗនៅតាមគំនរសំរាមបានមកចូលរៀនជារៀងរាល់ព្រឹក ដូចជាសិស្សសាលាដទៃទៀតដែរ ។ ពេលបើកបវេស្សនកាល អង្គការមានចែកជូននូវសំលៀកបំពាក់ សៀវភៅសរសេរ និងសៀវភៅពុម្ភ។ អង្គការធ្វើអោយគេយល់ពីតំលៃវប្បធម៌ខ្មែរតាមរយៈរបាំបូរាណ។

**៣-មណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ**
សាលាបង្រៀនកាត់សក់ ផ្នែកលេខាធិការ ធ្វើនំ អាហារដ្ឋាន និង សណ្ឋាគារ។

៤-**ការអប់រំខាងក្រៅអង្គការៈ** មានក្មេង ចំនួន ១៣00 នាក់ក្នុង ៦សាលាផ្សេងគ្នា


*សិស្សនៅមណ្ឌលភាពញញឹមនៃកុមារ ពេលលេងកីឡា*

តទៅទំព័រ ទី ៣